Australian Government
Department of Home Affairs

# សេវាកម្មពិសេស និងសេវាកម្មជំនាញកម្រិតខ្ពស់

## ការកែប្រែសេវាកម្មដោយសារជំងឺកូវីដ១៩

សេវាកម្មពិសេស និងសេវាកម្មជំនាញកម្រិតខ្ពស់
នៅតែមានបន្តសម្រាប់អតិថិជនក្នុងអំឡុងពេលមានជំងឺរាតត្បាតកូវីដ១៩។
ប៉ុន្តែរបៀបផ្តល់សេវានេះអាចមានការកែប្រែអាស្រ័យទៅលើឱវាទផ្លូវការរបស់វិស័យសុខាភិបាល។

សូមទាក់ទង **ស្ថាប័នផ្តល់សេវាកម្ម** របស់លោកអ្នកដោយផ្ទាល់ដើម្បីពិភាក្សានូវរបៀបចាត់ចែងថ្មីនេះ។

ស្វែងយល់អំពី **ជំងឺកូវីដ១៩ និងរោគសញ្ញារបស់វា**។

## ទិដ្ឋភាពរួម

ការមកតាំងទីលំនៅថ្មីដោយមនុស្សធម៌ (HSP) ផ្តល់នូវសេវាកម្មពិសេស និងសេវាកម្មជំនាញកម្រិតខ្ពស់ (SIS) ដែលអនុញ្ញាតឱ្យជនអន្តោប្រវេសន៍ដោយសារមនុស្សធម៌ និងអ្នកកាន់ទិដ្ឋាការដទៃទៀតដែលមានបញ្ហាស្មុគ្រស្មាញ។

សេវាកម្ម SIS ផ្តល់ជូនអតិថិជននូវជំនួយរយៈពេលខ្លីដោយផ្អែកលើសេចក្តីត្រូវការ ដើម្បីជួយឱ្យពួកគេទទួលបានសេវាចម្បងទាំងឡាយ និងដើម្បីអភិវឌ្ឍន៍ជំនាញដែលចាំបាច់ដើម្បីគ្រប់គ្រងសេចក្តីត្រូវការរៀងៗខ្លួនដោយឯករាជ្យ។ សេវាកម្ម SIS ផ្តល់ជូនដោយស្ថាប័នផ្តល់សេវា HSP ជូសឱ្យក្រសួងមហាផ្ទៃ (ហៅកាត់ថា ក្រសួង)។

ការិយាល័យ និងលេខទំនាក់ទំនងរបស់ស្ថាប័នផ្តល់សេវា HSP លោកអ្នកអាចស្វែងរកបាននៅ ទីនេះ។

## ភាពមានសិទ្ធិ

បុគ្គលដែលអាចកាន់ទិដ្ឋាការណាមួយក្នុងចំណោមទិដ្ឋាការខាងក្រោមនេះ អាចមានសិទ្ធិទទួលបានសេវា SIS ៖

- ទិដ្ឋាការជនភៀសខ្លួន (ប្រភេទលេខ 200, 201, 203 និង 204)
- ទិដ្ឋាការមនុស្សធម៌ពិសេសសកល (ប្រភេទលេខ 202)
- ទិដ្ឋាការការពារ (ប្រភេទលេខ 866)

- ទិដ្ឋាការការពារបណ្ដោះអាសន្ន (ប្រភេទលេខ 785) ទិដ្ឋាការស្នាក់នៅបណ្ដោះអាសន្នដោយកត្តាមនុស្សធម៌ (ប្រភេទលេខ 449) ទិដ្ឋាការបណ្ដោះអាសន្នដោយសារបញ្ហាមនុស្សធម៌ (ប្រភេទលេខ 786) និងទិដ្ឋាការគម្រោងជម្រកសុវត្ថិភាព(អនុប្រភេទលេខ 790)។

អ្នកកាន់ទិដ្ឋាការទាំងនេះអាចមានសិទ្ធិទទួលសេវាសម្រាប់រយៈពេលដល់ទៅ៥ឆ្នាំ ក្រោយពីគេបានមកដល់ប្រទេសអូស្ត្រាលី ឬអាចដល់៥ឆ្នាំបន្ទាប់ពីមានសិទ្ធទទួលទិដ្ឋាការនៅក្នុងប្រទេសអូស្ត្រាលី។

ក្នុងករណីពិសេសខ្លះ អ្នកកាន់ទិដ្ឋាការដូចបានរៀបរាប់ខាងលើអាចមានសិទ្ធិក្នុងការទទួលសេវា SIS ក្រោយពីរយៈពេលខាងលើ ឬ សិទ្ធិទទួលបានអាចនឹងផ្ដល់ជូនដល់អ្នកកាន់ទិដ្ឋាការដទៃៗទៀត។ អ្នកមានសញ្ជាតិអូស្ត្រាលីមិនមានសិទ្ធិទទួលសេវា SIS ឡើយ។

ជនដែលមានសិទ្ធិទទួលសេវា SIS ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ពួកគេពុំមានសមត្ថភាពពឹងពាក់សេវាសង្គមសមស្របដោយខ្លួនឯងបាន ហើយមានឧបសគ្គច្រើន និងស្មុគ្រស្មាញដែលរួមមាន៖

- ពិការភាព
- សេចក្ដីត្រូវការផ្នែកសុខភាពដែលមានលក្ខណៈធ្ងន់ធ្ងរ យូរអង្វែង និង/ឬ មិនមានអ្នកណាគ្រប់គ្រង
- បញ្ហាសុខភាពផ្លូវចិត្ត អារម្មណ៍ និងស្មារតី
- ពុំមានផ្ទះស្នាក់នៅ ឬ លំនៅដ្ឋានមិនច្បាស់លាស់
- អំពើហិង្សាក្នុងផ្ទះ និងក្នុងគ្រួសារ
- ការបារម្ភអំពីសុខុមាលភាពរបស់កុមារ និងជនវ័យជំទង់
- ការបែកបាក់គ្រួសារ និង/ឬ ស្វាមីភរិយា
- ការនៅដាច់ពីសង្គម
- ការលំបាកផ្នែកថវិកា
- បញ្ហាផ្លូវច្បាប់

## តើបុគ្គលណាមួយមានសិទ្ធិអាចណែនាំឱ្យមកទទួលសេវា SIS?

គ្រប់អង្គការ ស្ថាប័ន ឬ បុគ្គលណាក៏ដោយ ក៏អាចណែនាំមនុស្សណាក៏បានមកទទួលយកសេវាកម្ម SIS។ នេះគិតរួមទាំងការណែនាំខ្លួនឯងផងដែរ។

## តើត្រូវបញ្ជូនបុគ្គលណាម្នាក់ឱ្យទៅទទួលសេវា SIS ដោយវិធីណា

ដើម្បីបញ្ជូនឈ្មោះបុគ្គលណាម្នាក់ឱ្យទៅទទួលសេវា SIS សូមបំពេញតាម ទម្រង់ឯកសារបញ្ជូនឈ្មោះទៅ SIS ។

ប្រសិនបើលោកអ្នកមិនច្បាស់ថាជនណាម្នាក់មានសិទ្ធិ ឬ អត់ក្នុងការទទួលសេវា SIS ឬ លោកអ្នកត្រូវការជំនួយក្នុងការបំពេញឯកសារនេះ លោកអ្នកអាចទាក់ទងមកកាន់ SIS តាមលេខទូរស័ព្ទក្នុងម៉ោងធ្វើការ ក្នុងតំបន់ AEST 1300 855 669 (ការហៅក្នុងប្រទេសអូស្ត្រាលីពុំមានគិតថ្លៃទេ)។

ប្រសិនបើលោកអ្នកជួបការលំបាកផ្នែកបច្ចេកទេសក្នុងការបំពេញទម្រង់ឯកសារតាមអនឡាញ លោកអ្នកអាចសុំជំនួយដោយទាក់ទងទៅកាន់ការផ្តល់ជំនួយខាងប្រព័ន្ធ HSP ក្នុងម៉ោងធ្វើការតាមរយៈលេខ 1800 020 283 ឬ អ៊ីម៉េលទៅកាន់ hspsystem.helpdesk@dss.gov.au ។

ប្រសិនបើលោកអ្នកមិនអាចចូលទៅបំពេញទម្រង់ឯកសារតាមអនឡាញបាន លោកអ្នកអាចបំពេញវាជា **ក្រដាស** បាន។

## តើនឹងមានអ្វីនឹងកើតឡើងបន្ទាប់ពីដាក់ឯកសារហើយ

នៅពេលដែលក្រសួងទទួលបានឯកសារគ្រប់គ្រាន់ហើយ ក្រសួងនឹងពិនិត្យថាបុគ្គលនោះមានសិទ្ធិឬអត់ក្នុងការទទួលបានសេវានេះ ហើយនឹងផ្តល់ដំណឹងអំពីលទ្ធផលទៅឱ្យបុគ្គលនោះ។ ប្រសិនជាបុគ្គលនោះមានសិទ្ធិក្នុងការទទួលបានសេវាកម្មSIS ក្រសួងនឹងទាក់ទងទៅកាន់ស្ថាប័នដែលនឹងផ្តល់សេវា HSPទៅឱ្យបុគ្គលនោះ។

រយៈពេលដែលអតិថិជនទទួលសេវា SIS គឺអាស្រ័យទៅលើសេចក្តីត្រូវការរបស់ជននោះ ប៉ុន្តែជាទូទៅអាចដល់៦ខែ។